ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

# សេចក្តីណែនាំរបស់ក្រសួងសុខាភិបាល
# ស្តីពី
# ការបង្កើនការប្រុងប្រយ័ត្នបន្ថែមដើម្បីការពារការចម្លងមេរោគកូវីដ-១៩

ក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា សូមជម្រាបជូនសាធារណៈជនទាំងអស់ឱ្យបានជ្រាបថា ស្ថានភាពនៃការចម្លងនៃវីរុសកូវីដ-១៩ នៅបណ្តាប្រទេសលើសកលលោក និងក្នុងតំបន់មិនទាន់មានការធូរស្បើយនៅឡើយជាក់ស្តែងរហូតមកដល់ថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០២១ នៅលើពិភពលោក មានករណីជំងឺកូវីដ-១៩ ចំនួន ២២០លាន៥៦៣ពាន់ ២២៧នាក់ ដែលក្នុងនោះមានអ្នកស្លាប់ចំនួន ៤លាន ៥៦៥ពាន់ ៤៨៣នាក់ ដែលបានរាយការណ៍មកអង្គការសុខភាពពិភពលោក ឯបណ្តាប្រទេសដែលមានភូមិផងរបងជាប់យើងវិញក៏នៅតែមានការចម្លងខ្ពស់នៅឡើយទោះបីជាមានការថយចុះបន្តិចក៏ដោយ។ ចំណែកព្រះរាជាណាចក្រកម្ពុជាយើង ដោយមានកិច្ចខិតខំប្រឹងប្រែងពីសំណាក់ប្រមុខរាជរដ្ឋាភិបាលដែលមាន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បានដឹកនាំចង្អុលបង្ហាញផ្លូវ ប្រកបដោយគតិបណ្ឌិតខ្ពស់ ដែលបានធ្វើឱ្យករណីឆ្លងជំងឺកូវីដ-១៩ បន្តធ្លាក់ចុះជាបន្តបន្ទាប់ជាទីមោទនៈក្នុងអំឡុងខែសីហារហូតដល់ដើមខែកញ្ញានេះ។ ដោយឡែកនាប៉ុន្មានថ្ងៃចុងក្រោយនេះ យើងសង្កេតឃើញថាចំនួនករណីជំងឺ កូវីដ-១៩ មានការហក់ឡើងបន្តិចនៅតាមបណ្តាខេត្តមួយចំនួន ដែលក្នុងនោះក្រសួងសុខាភិបាលបានរកឃើញថាករណីផ្ទុះភាគច្រើនបានកើតឡើងនៅទីផ្សារលក់ដូរ ដែលមិនមែនជាផ្សារទំនើប គឺផ្សារលក់ដូរនៅតាមបណ្តាខេត្ត ក្រុង ភូមិ ទីប្រជុំជននានាជាដើម ដែលបងប្អូនប្រជាពលរដ្ឋយើងមានការទៅទិញម្ហូបអាហារ និងគ្រឿងឧបភោគបរិភោគ ឬជួបជុំគ្នាបរិភោគជាដើម។ អាស្រ័យហេតុនេះ ដើម្បីធានាឱ្យបាននូវការទប់ស្កាត់ការចម្លងជំងឺកូវីដ-១៩ និងឆ្ពោះទៅកាន់ការរស់នៅតាមបែបគន្លងប្រក្រតីភាពថ្មី ក្រសួង សុខាភិបាលសូមអំពាវនាវ ដល់លោកអ៊ំ ពូ មីង ពុក ម៉ែ បងប្អូនទាំងអស់កុំមានអារម្មណ៍ស្ពប់ស្ពល់ ដោយមានការពឹងផ្អែកទាំងស្រុងទៅលើវ៉ាក់សាំងដែលលោកអ៊ំ ពូ មីង ពុក ម៉ែ បងប្អូនទាំងអស់ បានទទួលនោះទេ ពីព្រោះតាមរយៈអង្គការ សុខភាពពិភពលោកដែលបានចុះផ្សាយ ៖ "វ៉ាក់សាំងមានប្រសិទ្ធភាព ការពារយើងមិនឱ្យឈឺធ្ងន់ធ្ងរដែលតម្រូវឲ្យសម្រាកពេទ្យ និងកាត់បន្ថយហានិភ័យនៃការស្លាប់ដោយសារជំងឺកូវីដ-១៩ ប៉ុន្តែលទ្ធភាពចម្លងវីរុសកូវីដ-១៩ ចំពោះបុគ្គលដែលបានចាក់វ៉ាក់សាំងរួច គឺនៅតែអាចឆ្លងបានប្រសិនបើបុគ្គលនោះមិនបានអនុវត្តនូវវិធានការបង្ការការចម្លងវីរុសកូវីដ-១៩ បានខ្ជាប់ខ្ជួនទេនោះ។ ភស្តុតាងពីបណ្តាប្រទេសនៅលើពិភពលោកទាំងអស់ក៏ទទួលស្គាល់ដែរថា វ៉ាក់សាំងមានសារៈសំខាន់ណាស់ក្នុងការទប់ស្កាត់ការចម្លងកូវីដ-១៩ ដោយបង្ការបុគ្គលមិនឲ្យកើតជំងឺកូវីដ-១៩ ធ្ងន់ធ្ងរ និងកាត់បន្ថយហានិភ័យនៃការស្លាប់ដោយសារជំងឺនេះ ទោះបីជាបានចាក់វ៉ាក់សាំងការពារវីរុសកូវីដ-១៩ រួចហើយក៏ដោយ ក៏បុគ្គលគ្រប់រូបត្រូវអនុវត្តវិធានការសុខាភិបាលជាចាំបាច់ដើម្បីបង្ការការឆ្លងវីរុសកូវីដ-១៩ ចូលក្នុងខ្លួន គ្រួសារ និងសហគមន៍។ ជាបន្ថែមទៀត បណ្តាប្រទេសទាំងអស់នៅលើពិភពលោក ក៏បាននិងកំពុងទទួលស្គាល់ថា វីរុសកូវីដ-១៩ បន្តបំប្លែងខ្លួនជាច្រើនបែបច្រើនយ៉ាង តួយ៉ាងដូចជា វីរុសកូវីដ-១៩ បំប្លែងថ្មីប្រភេទដែលតា(Delta) ដែលបាននិងកំពុងរាលដាលយ៉ាងលឿននៅបណ្តាប្រទេសជាង១៣០ប្រទេស រួមទាំងប្រទេសកម្ពុជាយើងផងដែរ ដែលមានចំនួនករណីជំងឺកូវីដ-១៩ បង្កដោយវីរុសបំប្លែងថ្មីប្រភេទ "ដែលតា" នេះ មានការកើនឡើងជារៀងរាល់ថ្ងៃដែលគួរឱ្យមានការព្រួយបារម្ភជាខ្លាំង។

ដូច្នេះក្រសួងសុខាភិបាល សូមអំពាវនាវ និងក្រើនរំលឹកដល់បងប្អូនប្រជាពលរដ្ឋទាំងអស់ ចូលរួមទទួលខុសត្រូវទប់ស្កាត់ការចម្លងវីរុសកូវីដ-១៩ ដោយ បុគ្គល គ្រួសារ សហគមន៍ អាជ្ញាធរមូលដ្ឋានត្រូវបង្កើនការប្រុងប្រយ័ត្នខ្ពស់និងអនុវត្តឱ្យបានខ្ជាប់ខ្ជួននូវ វិធានការ **៣ការពារ** ( ពាក់ម៉ាស់ លាងដៃឱ្យញឹកញាប់ និងរក្សាគម្លាតសុវត្ថិភាពបុគ្គលពីមួយម៉ែត្រកន្លះឡើង) និង**៣កុំ** (កុំទៅកន្លែងមានមនុស្សច្រើន កុំទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល កុំប៉ះពាល់គ្នា កុំចាប់ដៃគ្នា កុំកៀកស្មាគ្នា) តាមការណែនាំដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ព្រមទាំងយកចិត្តទុកដាក់ខ្ពស់តាមដានការអនុវត្តន៍វិធានការសុខាភិបាលនៅតាមទីតាំងនានា ជាពិសេសទីតាំងមានហានិភ័យខ្ពស់ ដូចជាទីតាំង ៣-ជ- (ទីតាំងមានមនុស្សច្រើនជួបជុំ ទីតាំងបិទជិតមិនមានខ្យល់ចេញចូលគ្រប់គ្រាន់ និងទីតាំងដែលមានមនុស្សនៅជិតៗគ្នា) និងចាត់វិធានការរដ្ឋបាលសមស្របចាំបាច់។ ការចូលរួមរបស់បុគ្គល និងសហគមន៍ក្នុងការទប់ស្កាត់ការចម្លងវីរុសកូវីដ-១៩នៅតែចាំបាច់បំផុតនិងត្រូវអនុវត្តជាប់ជាប្រចាំទោះជាបងប្អូនទាំងអស់បានចាក់វ៉ាក់សាំងរួចហើយក៏ដោយ។

ក្រសួងសុខាភិបាល និងបន្តធ្វើការជូនដំណឹងដល់សាធារណជន អំពីការវិវត្តន៍នៃបញ្ហាសុខភាពតាមទំព័រហ្វេសប៊ុក និងគេហទំព័ររបស់ក្រសួងសុខាភិបាល www.cdcmoh.gov.kh ដែលគេហទំព័រនេះមានសម្ភារអប់រំសុខភាព ដែលអាចទាញយកមកមើល និងប្រើប្រាស់បាន។ សំរាប់ព័ត៌មានបន្ថែម សូមទាក់ទងលេខទូរស័ព្ទទាន់ហេតុការណ៍ ក្រសួងសុខាភិបាល លេខ ១១៥ ដោយឥតគិតថ្លៃ ឬទំនាក់ទំនងក្រសួងសុខាភិបាល តាមលេខទូរស័ព្ទ៖ ០១២ ៤៨៨ ៩៨១ ឬ ០១២ ៨៣៦ ៨៦៨។

ថ្ងៃចន្ទ ៧កើត ខែភទ្របទ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០២១